**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងឱកាសទិវាប្រជាជនពិភពលោកលើកទី៣១ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០

*សូមក្រាបថ្វាយបង្គំ សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!*
*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី!*
*ជនរួមជាតិជាទីស្រឡាញ់រាប់អាន!*

ថ្ងៃនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមថ្លែងទៅកាន់សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទាំងអស់ថា ប្រជាជនកម្ពុជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយនឹងប្រជាជាតិទូទាំងពិភពលោក ប្រារព្ធ «**ទិវាប្រជាជនពិភពលោកលើកទី៣១**»។ អង្គការសហប្រជាជាតិតែងតែលើកទឹកចិត្តដល់បណ្តារដ្ឋភាគីទាំងអស់ឱ្យប្រារព្ធទិវាប្រជាជនពិភពលោកជារៀងរាល់ឆ្នាំនៅថ្ងៃទី១១ ខែកក្កដា ដោយផ្តោតលើប្រធានបទផ្សេងៗគ្នា។ ប្រធានបទឆ្នាំ២០២០នេះ គឺ «**ការបញ្ឈប់ការរីករាលដាលជំងឺកូវីដ-១៩: តើពេលនេះយើងត្រូវការពារសុខភាពនិងសិទ្ធិរបស់ស្ត្រីនិងក្មេងស្រីរបៀបណា** ("Putting the breaks on Covid-19: how to safeguard the health and rights of women and girls now")។ ប្រធានបទនេះពិតជាមានអត្ថន័យធំធេងក្នុងស្ថានភាពដែលពិភពលោកទាំងមូលកំពុងប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ (កូវីដ-១៩) ដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវិតមនុស្ស សហគមន៍ និងសេដ្ឋកិច្ចសង្គមនៅគ្រប់ទិសទីទូទាំងពិភពលោក។

ជំងឺកូវីដ-១៩ ចាប់ផ្តើមកើតមានដំបូងនៅចុងឆ្នាំ២០១៩ នៅទ្វីបអាស៊ី និងបានរីករាលដាលជាសាកល ហើយករណីឆ្លងថ្មីកំពុងបន្តកើនជារៀងរាល់ថ្ងៃ។ គិតត្រឹមសប្តាហ៍ទី១នៃខែកក្កដា ឆ្នាំ២០២០នេះ អ្នកឆ្លងជំងឺកូវីដ-១៩ នៅទូទាំងពិភពលោកបានកើនដល់ជាង១១លានករណី និងមានអ្នកស្លាប់រហូតដល់ជាងកន្លះលាននាក់។ ប្រទេសនៅលើពិភពលោកដែលមានករណីឆ្លងជំងឺកូវីដ-១៩ច្រើនជាងគេ មានដូចជា សហរដ្ឋអាម៉េរិក ប្រទេសប្រេស៊ីល ប្រទេសរុស្ស៊ី ប្រទេសឥណ្ឌា និងប្រទេសប៉េរូ។ ចំពោះប្រទេសក្នុងតំបន់អាស៊ានវិញ ប្រទេសដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ច្រើនជាងគេក្នុងតំបន់ រួមមាន ប្រទេសឥណ្ឌូណេស៊ី ប្រទេសសិង្ហបុរី និងប្រទេសហ្វីលីពីន។

ជំងឺកូវីដ-១៩ បានបង្កបញ្ហាប្រឈមដល់មនុស្សគ្រប់គ្នានៅលើពិភពលោក ក្នុងនោះស្ត្រីជាមុខសញ្ញាចម្បងដែលអាចទទួលរងការប៉ះពាល់មុនគេ ជាពិសេសបុគ្គលិកសុខាភិបាលជួរមុខជាស្ត្រី។ ជាក់ស្តែង ថ្មីៗនេះការសិក្សាស្រាវជ្រាវរបស់អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) បង្ហាញថាប្រសិនបើវិធានការបង្ខាំង បន្តរយៈពេល៦ខែទៀត ហើយការផ្តល់សេវាសុខាភិបាលមិនបានពេញលេញដោយសារជំងឺកូវីដ-១៩ ពេលនោះនឹងមានស្ត្រីជាង៤៧លាននាក់នៅក្នុងបណ្តាប្រទេសដែលមានចំណូលទាបនិងចំណូលមធ្យមនឹងមិនអាចទទួលបានសេវាពន្យារកំណើតទំនើប ដែលជាលទ្ធផល ស្ត្រីប្រហែល៧លាននាក់នឹងអាចមានផ្ទៃពោះមិនតាមប្រាថ្នា ហើយអំពើហិង្សាផ្អែកលើយេនឌ័រនឹងអាចកើតមានប្រហែល៣១លានករណីបន្ថែមទៀត។ លើសពីនេះទៀត បើធៀបនឹងបុរស ស្ត្រីធ្វើការនៅក្នុងទីផ្សារពលកម្មដែលមិនសូវមានសុវត្ថិភាពត្រូវរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរជាង ពីវិបត្តិកូវីដ-១៩។ ស្ត្រីជិត៦០% នៅទូទាំងពិភពលោកកំពុងធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលងាយរងហានិភ័យខ្ពស់ក្នុងការធ្លាក់ចូលក្នុងភាពក្រីក្រ។ ការងារថែទាំដែលមិនមានប្រាក់កម្រៃរបស់ស្ត្រីមានការកើនឡើង ដោយសារការបិទសាលារៀននិងការកើនឡើងនៃតម្រូវការរបស់មនុស្សវ័យចាស់។ ជំងឺឆ្លងកូវីដ-១៩ កំពុងវាយលុកសហគមន៍ដែលងាយរងគ្រោះ ជាពិសេស ការកើតមានវិសមភាពកាន់តែខ្លាំង និងការរារាំងដល់កិច្ចខិតខំប្រឹងប្រែងសម្រេចគោលដៅរួមរបស់យើងគឺ **«ការកសាងពិភពលោកមួយដែលគ្មាននរណាម្នាក់ត្រូវបានបំភ្លេចចោល»**។

*ព្រះវររាជានុភាពគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់!*

ជំងឺឆ្លងកូវីដ-១៩ នៅតែបង្កើនការវាយលុកទៅលើពិភពលោកយ៉ាងខ្លាំងនិងមិនទាន់បង្ហាញឱ្យឃើញនូវសញ្ញាធូរស្រាលណាមួយឡើយ សុខភាពសាធារណៈសកលនឹងជួបវិបត្តិកាន់តែខ្លាំងឡើង និងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ។ ប្រទេសទាំងអស់នៅលើពិភពលោកបាននិងកំពុងទទួលរងនូវផលប៉ះពាល់នេះ ដែលតម្រូវឱ្យរដ្ឋាភិបាលនៃប្រទេសទាំងឡាយរៀបចំកែសម្រួលនូវគោលនយោបាយនិងយុទ្ធសាស្ត្ររៀងៗខ្លួនស្របតាមស្ថានភាពជាក់ស្តែងរបស់ប្រទេសនីមួយៗ។

ក្នុងការឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រនិងវិធានការច្បាស់លាស់ ព្រមទាំងបាននិងកំពុងអនុវត្តយ៉ាងម៉ឺងម៉ាត់ ដើម្បីការពារសុខុមាលភាពប្រជាជន ដែលជាលទ្ធផលយើងទទួលបានជោគជ័យ។ ជាក់ស្តែងគិតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២០ ប្រទេសកម្ពុជា មានករណីឆ្លងជំងឺកូវីដ-១៩ចំនួន១៤១នាក់ បានព្យាបាលជាសះស្បើយចំនួន១៣១នាក់ កំពុងសម្រាកព្យាបាលចំនួន១០នាក់ និងមិនមានករណីអ្នកស្លាប់ទេ។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានដាក់ករណីជំងឺកូវីដ-១៩នេះទៅក្នុងក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ព្រមទាំងបានណែនាំប្រជាជនឱ្យចូលរួមការពារសុខភាពដើម្បីចៀសវាងពីការឆ្លងជំងឺកូវីដ-១៩ ដែលជាគោលនយោបាយគន្លឹះតាមរយៈការចូលរួមទាំងអស់គ្នា។ ឯកឧត្តម **តេដ្រូ អើឌហានូម ហ្គេប្រេយេសស៊ុស (Tedros Adhanom Ghebreyesus)** អគ្គនាយកអង្គការសុខភាពពិភពលោក (WHO) ក៏បានប្រកាសគាំទ្រចំពោះវិធានការនិងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩។

ជាមោទនភាព ប្រជាជនកម្ពុជាទូទាំងប្រទេសបានសម្តែងនូវស្មារតីសាមគ្គីភាព តាមរយៈវប្បធម៌នៃការចែករំលែកគ្នាក្នុងគ្រាលំបាក តាមរយៈការចូលរួមបរិច្ចាគថវិកាផ្ទាល់ខ្លួនជាមួយនឹងគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ (COVID-19) ដែលត្រូវបានបង្កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០។ ជាក់ស្តែង គិតត្រឹមសប្តាហ៍ទីមួយនៃខែកក្កដា ឆ្នាំ២០២០ ថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ អាជីវករ និងប្រជាពលរដ្ឋ ចំនួនជិត៨ម៉ឺននាក់ បានចូលរួមវិភាគទានប្រាក់រៀលនិងប្រាក់ចំណូលផ្ទាល់ខ្លួនដោយស្ម័គ្រចិត្តជូនដល់មូលនិធិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយមានទឹកប្រាក់សរុបកើនដល់ជិត៤២៣ពាន់លានរៀល ឬប្រហាក់ប្រហែលជាង១០លានដុល្លារសហរដ្ឋអាមេរិក។

ជាមួយគ្នានេះដែរ ក្នុងវិស័យសង្គមកិច្ច រាជរដ្ឋាភិបាលកម្ពុជាបានបន្តជំរុញអនុវត្តគោលនយោបាយគាំពារសង្គមនិងបានដាក់ចេញវិធានការអន្តរាគមន៍ជំនួយសង្គមបន្ថែមទៀត សំដៅជួយសម្រាលការលំបាក និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដែលមានជីវភាពក្រីក្រ ជាពិសេសស្ត្រីនិងក្មេងស្រី នៅក្នុងពេលមានវិបត្តិនៃជំងឺកូវីដ-១៩ ដូចជា ការឧបត្ថម្ភចំពោះកម្មការិនីដែលជាស្ត្រីមានផ្ទៃពោះនិងគ្រួសារដែលមានជីវភាពក្រីក្រ ការបង្កើនមូលធនថវិកា «សាច់ប្រាក់ពលកម្ម» ដើម្បីជួយដល់កម្មករនិយោជិតដែលបានព្យួរការងារអំឡុងពេលដែលរោងចក្រសហគ្រាស គ្រឹះស្ថាន ក្នុងវិស័យកាត់ដេរ និងទេសចរណ៍មួយចំនួនបានផ្អាកដំណើរការ និងកម្មវិធីជំនួយសង្គមថ្មីមួយទៀត ដែលជាកម្មវិធីជំនួយសង្គមពិសេស គឺ **«កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩»** ដែលបានប្រកាសឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០កន្លងទៅនេះ សំដៅជួយដល់ប្រជាជនដែលមានជីវភាពក្រីក្រនិងងាយរងគ្រោះដែលមានប័ណ្ណសមធម៌ (ក្រ-១ និង ក្រ-២)។

នៅក្នុងវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញវិធានការអន្តរាគមន៍ចំនួន៤ជុំរួចមកហើយ ដែលវិធានការអន្តរាគមន៍ទាំងនោះ មានដូចជា ការអនុគ្រោះពន្ធ ការអនុញ្ញាតមិនឱ្យបង់ប្រាក់វិភាគទានធានារ៉ាប់រងហានិភ័យការងារនិងថែទាំសុខភាព ការផ្តល់ភាពអនុគ្រោះលើលក្ខខណ្ឌឥណទាន ការបង្កើនសន្ទនីយភាពនៅក្នុងទីផ្សារ ការផ្តល់ប្រាក់ឧបត្ថម្ភរយៈពេល២ខែសម្រាប់កម្មករ បុគ្គលិក ក្នុងវិស័យកាត់ដេរនិងទេសចរណ៍ ការរៀបចំកម្មវិធីហិរញ្ញប្បទានពិសេសដើម្បីជួយស្តារលទ្ធភាពនិងលើកកម្ពស់អាជីវកម្មសហគ្រាសធុនតូចនិងមធ្យម ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញ និងការរៀបចំគម្រោងហិរញ្ញប្បទានសម្រាប់ទុនបង្វិលដើម្បីបំពេញតម្រូវការរបស់រោងចក្រ សហគ្រាស និងអាជីវកម្មទាំងអស់។

***ព្រះវេជ្ជានុភាពព្រះគុណព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ!***

បើពិនិត្យជារួម ការរីករាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលកម្ពុជាអាចគ្រប់គ្រងសភាពការណ៍បានល្អប្រសើរ ហើយសង្គមជាតិយើងទាំងមូលនៅតែបន្តតស៊ូប្រយុទ្ធប្រឆាំងនឹងការឆ្លងរាតត្បាតជំងឺកូវីដ-១៩នេះ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តបន្តកិច្ចខិតខំប្រឹងប្រែងនិងពង្រឹងកិច្ចសហការល្អជាមួយនឹងស្ថាប័នរបស់អង្គការសហប្រជាជាតិនិងប្រទេសជាដៃគូទាំងអស់ ជាពិសេស អង្គការសុខភាពពិភពលោក ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងកូវីដ-១៩ សំដៅលុបបំបាត់ទាំងស្រុងជំងឺកូវីដ-១៩ និងការពារសុខុមាលភាពរបស់ប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនក្នុងពិភពលោក។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរគុណដល់ជនរួមជាតិទាំងអស់ ជាពិសេសមន្ត្រីសុខាភិបាលជួរមុខ ដែលបានចូលរួមគាំទ្រនិងរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះអង្គការសហប្រជាជាតិ ជាពិសេសអង្គការសុខភាពពិភពលោក និងបណ្តាប្រទេសជាមិត្តទាំងអស់ដែលបានគាំទ្រដល់កម្ពុជា ទាំងស្មារតី ទាំងសម្ភារៈសុខាភិបាល និងវិធីសាស្ត្រព្យាបាលនិងទប់ស្កាត់ការឆ្លងកូវីដ-១៩ ជាពិសេស សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន និងសហរដ្ឋអាម៉េរិក ដែលបានគាំទ្រដល់ប្រជាជនកម្ពុជានៅក្នុងស្ថានភាពដ៏លំបាកនេះ។

ជាទីបញ្ចប់នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរ ប្រគេនពរ និងជូនពរដល់សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ព្រហស្បតិ៍ ៤រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ២០២០

**ហ៊ុន សែន**